# គោលនយោបាយ

# យុវជនកាកបាទក្រហមកម្ពុជា

**អនុម័តដោយអង្គសន្និបាតយុវជនកាកបាទក្រហមកម្ពុជា លើកទី៣**

**៥ សីហា ឆ្នាំ ២០១៤**

កាកបាទក្រហមកម្ពុជា ឡូត៍ ១៦A ផ្លូវ ៦៥៤ កែង ២៧១ អូរបែកក្អម សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (855-23) 881 511, ទូរសារ: (855-23) 881 522, P.O.Box:69
វេបសាយ : www.redcross.org.k, អ៊ីម៉ែល: info@redcross.org.kh, crc_adm@online.com.kh

បោះពុម្ពជាភាសាខ្មែរ និងអង់គ្លេស ចំនួន ១៧៥០ ច្បាប់ ឧបត្ថម្ភដោយ ៖ Australian Red Cross THE POWER OF HUMANITY
ខែ តុលា ឆ្នាំ ២០១៤

# មាតិកា

ទំព័រ

១. សេចក្តីផ្តើម ........................................ ១

២. ទស្សនវិស័យ ........................................ ៥

៣. គោលបំណង ........................................ ៥

៤. ទិសដៅ ........................................ ៥

៥. យុទ្ធសាស្ត្រ ........................................ ៦

៦. ផែនការសកម្មភាព ........................................ ៧

៧. ពិនិត្យ តាមដាន និងវាយតម្លៃ ........................................ ១០

៨. សេចក្តីសន្និដ្ឋាន ........................................ ១០

# គោលនយោបាយ
# យុវជនកាកបាទក្រហមកម្ពុជា

## ១. សេចក្តីផ្តើម

កាកបាទក្រហមកម្ពុជា ត្រូវបានបង្កើតឡើងនៅ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៥៥ ដែលត្រូវបានទទួលស្គាល់ដោយព្រះរាជក្រិត្យលេខ ៣៧៨/នស ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៥៨ និងព្រះរាជក្រិត្យលេខ នស/ រកត ០៥០២/១១៣ ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០០២ និងបាន ទទួលស្គាល់ពីគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម នៅថ្ងៃទី ៧ ខែ តុលា ឆ្នាំ ១៩៦០ និងត្រូវបានបញ្ចូលជាសមាជិកទី ៨៥ របស់សហព័ន្ធ អន្តរជាតិ នៃសមាគមជាតិកាកបាទក្រហម អឌ្ឍចន្ទក្រហម នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ១៩៦០។

បច្ចុប្បន្ន កាកបាទក្រហមកម្ពុជា ជាស្ថាប័នមនុស្សធម៌ធំជាងគេ ក្នុងប្រទេស ធ្វើប្រតិបត្តិការជួយសង្គ្រោះ និងសម្រាលទុក្ខលំបាករបស់ ប្រជាពលរដ្ឋរងគ្រោះ និងងាយរងគ្រោះ ដោយគណៈអភិបាល ក្រុម ប្រតិបត្តិ អ្នកស្ម័គ្រចិត្ត យុវជនកាកបាទក្រហម នៅក្នុងរចនាសម្ព័ន្ធដ៏រឹង មាំ ពីថ្នាក់ជាតិដល់សហគមន៍មូលដ្ឋាន ដោយមានការជួយឧបត្ថម្ភគាំទ្រ ពីរាជរដ្ឋាភិបាល ពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដៃគូសហប្រតិបត្តិការ ស្ថាប័នពាក់ព័ន្ធ និងសប្បុរសជនជាតិ-អន្តរជាតិ។

កាកបាទក្រហមកម្ពុជា មានកម្លាំងអ្នកស្ម័គ្រចិត្តរាប់ម៉ឺននាក់ បាន នឹងកំពុងអនុវត្តនូវការងារមនុស្សធម៌ដ៏មានតម្លៃនេះ នៅក្នុងចំណោមនោះ យុវជនកាកបាទក្រហមកម្ពុជា ដែលជាអ្នកស្ម័គ្រចិត្តវ័យក្មេង ត្រូវបាន ទទួលស្គាល់ជាកម្លាំងស្នូលមួយដ៏មានសារៈសំខាន់ និងសកម្មបំផុត នៅ

ក្នុងការផ្តល់នូវសេវាកម្មមនុស្សធម៌ ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ និងការលះបង់ឥតងាករេស្របតាមប្រធានបទ«**សង្គ្រោះជីវិត ផ្លាស់ប្តូរផ្នត់គំនិត**» នៃយុទ្ធសាស្ត្រ ២០១១-២០២០ របស់កាកបាទក្រហមកម្ពុជា ហើយនៅគ្រប់សម័យកាល គ្រប់សង្គម យុវជនមិនត្រឹមតែជាកម្លាំងដ៏ស្រួចស្រាវមានកម្លាំងកាយ កម្លាំងចិត្ត និងស្មារតីភ្លឺស្វាង មានទឹកចិត្តក្លាហានពុះពារគ្រប់ឧបសគ្គ និងទុក្ខលំបាកនានា មិនត្រឹមតែគ្មានការរារែកប៉ុណ្ណោះទេ ប៉ុន្តែយុវជនគឺជាសរសៃទ្រូងរបស់ប្រទេសជាតិ នាពេលបច្ចុប្បន្ន និងអនាគត។

ព្រះរាជាណាចក្រកម្ពុជា ចាត់ទុកយុវជនជាធនធានគន្លឹះ និងមានតម្លៃបំផុតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន និងការរក្សាសន្តិភាពទាំងបច្ចុប្បន្ន និងអនាគត។ នៅក្នុងបរិបទសង្គម វប្បធម៌ និងនយោបាយរបស់កម្ពុជា ***«យុវជន»*** ជាបុរស និងស្ត្រី អាយុពី១៥ ដល់ ៣០ ឆ្នាំ នៅលីវ ឬរៀបការហើយ។ យោងតាមជំរឿនទូទៅនៃប្រជាសាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨ យុវជនមានជាង ៥០ %នៃចំនួនប្រជាជនសរុប។ ដោយឡែកនៅក្នុងបរិបទកាកបាទក្រហមកម្ពុជា ***«យុវជន»*** គឺសំដៅដល់បុរស និងស្ត្រី ដែលមានអាយុចាប់ពី ៩ ដល់ ៣០ ឆ្នាំ សិក្សានៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន ពីកម្រិតបឋមសិក្សា រហូតដល់ឧត្តមសិក្សា។ នៅក្នុងខែឧសភា ឆ្នាំ២០១៤ យុវជនកាកបាទក្រហមកម្ពុជា មានចំនួនសរុប **២៩,០៩៩នាក់** នៅតាមគ្រឹះស្ថានសិក្សា ក្នុង ២៥ រាជធានី-ខេត្ត និងអ្នកស្ម័គ្រចិត្តសរុបចំនួន **២០,៤៥៦ នាក់** ទូទាំងប្រទេស។

តាមរយៈការអប់រំ ការផ្តល់នូវសិទ្ធិសម្រេចការងារនៅក្នុងគ្រប់កម្រិតនៃការគ្រប់គ្រង និងការបង្កលក្ខណៈ បរិយាកាសដ៏សមរម្យ គឺជាភាពសំខាន់ក្នុងការលើកទឹកចិត្តដល់យុវជនឱ្យចូលរួមយ៉ាងសកម្មថែមទៀត។ យុវជនបំពេញការងារក្នុងស្មារតី គោរពគ្នាទៅវិញទៅមក ជាមួយនឹងអ្នកដែលមានវ័យច្រើនជាង ក្នុងការធានាបាននូវការផ្ទេរបទពិសោធន៍ និងចំណេះដឹងពីមួយជំនាន់ទៅមួយជំនាន់ទៀត ដែលនេះគឺជាកត្តាជំរុញឱ្យមាននូវវឌ្ឍនភាព និងប្រសិទ្ធភាពការងាររបស់សមាគមជាតិ។ ទន្ទឹមនេះ យុវជនអាចចាប់យកនូវតួនាទីជាអ្នកដឹកនាំ សំដៅជំរុញឱ្យមានការផ្លាស់ប្តូរផ្នត់គំនិត អាកប្បកិរិយា និងអត្តចរិត នៅក្នុងសហគមន៍ពួកគេ។

ជាមួយនឹងគុណសម្បត្តិ និងកាលានុវត្តភាពដ៏ធំធេងរបស់យុវជនកាកបាទក្រហមកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា បានផ្តោតការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីធ្វើការអភិវឌ្ឍយុវជនកម្ពុជា ឱ្យក្លាយជាធនធានមនុស្សដ៏មានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ ព្រមទាំងប្រកបដោយទឹកចិត្តមនុស្សធម៌ សំដៅចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជា។

គោលនយោបាយយុវជនកាកបាទក្រហមកម្ពុជា ដែលបានពិនិត្យ និងអនុម័តដោយសន្និបាតយុវជន លើកទី៣ ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១៤ នេះ មានមូលដ្ឋានពីគោលនយោបាយយុវជនកាកបាទក្រហមកម្ពុជា ដែលបានអនុម័តដោយសន្និបាតយុវជនលើកទី១ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៦ និងសន្និបាតយុវជន លើកទី២ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១០។ គោលនយោបាយយុវជនកាកបាទក្រហមកម្ពុជានេះ ត្រូវបាន

បន្សុំទៅតាមគោលនយោបាយយុវជន របស់សហព័ន្ធអន្តរជាតិកាកបាទក្រហម អឌ្ឍចន្ទក្រហម ដែលបានអនុម័តដោយមហាសន្និបាត លើកទី១៨ កាលពីខែ វិច្ឆិកា ឆ្នាំ ២០១១ នាទីក្រុងហ្សឺណែវ និងត្រូវបានបន្សុំតាមគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១។

អនុវត្តយុទ្ធសាស្ត្រ ២០១១-២០២០ គោលនយោបាយយុវជនកាកបាទក្រហមកម្ពុជា មានទិសដៅបន្តទាក់ទាញឱ្យយុវជនចូលរួមកាន់តែច្រើនឡើងៗ ក្នុងសកម្មភាពមនុស្សធម៌ និងជំរុញឱ្យមានការយកចិត្តទុកដាក់លើការអប់រំ បណ្តុះបណ្តាល លើកទឹកចិត្ត កសាងសមត្ថភាពអភិវឌ្ឍយុវជន បង្កលក្ខណៈអំណោយផលឱ្យយុវជនកាន់តែសកម្មខ្លាំងជាងមុន ក្នុងការដឹកនាំគ្រប់គ្រងការស្ម័គ្រចិត្តផ្តល់សេវាកម្ម តាមវិស័យស្នូលទាំង ៤ «គ្រប់គ្រងគ្រោះមហន្តរាយ សុខភាពនិងការថែទាំសុខភាពតាមសហគមន៍ ការលើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌របស់ចលនា និងអភិវឌ្ឍស្ថាប័ន អភិវឌ្ឍធនធាន» ជួយសម្រាលទុក្ខលំបាករបស់ប្រជាពលរដ្ឋងាយរងគ្រោះ ដោយប្រកាន់ខ្ជាប់គោលការណ៍គ្រឹះទាំង ៧ របស់ចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម៖ ភាពមនុស្សធម៌ ភាពមិនលំអៀង អព្យាក្រឹត្យភាព ឯករាជភាព សេវាកម្មស្ម័គ្រចិត្ត ឯកភាព និងសកលភាព។

គោលនយោបាយយុវជន នេះគូសបញ្ជាក់ពីការទទួលស្គាល់តួនាទីដ៏មានសារៈសំខាន់របស់យុវជន និងគុណតម្លៃរបស់យុវជន នៅក្នុងការចូលរួមចំណែក ជាមួយអ្នកមានវ័យចម្រុះមកពីគ្រប់មជ្ឈដ្ឋាន ខិតខំប្រឹងប្រែងរួមគ្នាពុះពារដោះស្រាយរាល់បញ្ហាប្រឈមនានា។

## ២. ទស្សនវិស័យ

រួមចំណែកពន្លឿនដល់ការកាត់បន្ថយភាពក្រីក្រ ការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងការពារតម្លៃមនុស្សធម៌របស់ជនរងគ្រោះ។

## ៣. គោលបំណង

ជំរុញ និងលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម ដើម្បីអភិវឌ្ឍ និងប្រើប្រាស់សក្តានុពលរបស់យុវជនក្នុងការផ្តល់សេវាកម្មមនុស្សធម៌ តាមវិស័យស្នូលរបស់កាកបាទក្រហមកម្ពុជា រួមមាន៖ ១.ការគ្រប់គ្រងគ្រោះមហន្តរាយ ២.សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍ ៣.ការលើកកម្ពស់គោលការណ៍គ្រឹះរបស់ចលនា និងតម្លៃមនុស្សធម៌ ៤.ការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍធនធាន ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រ ២០១១-២០២០។

## ៤. ទិសដៅ

៤.១. ផ្តល់ឱកាសឱ្យយុវជន ទទួលបាននូវការអប់រំ បណ្តុះបណ្តាល បង្កើនសមត្ថភាព ក្នុងគុណតម្លៃមនុស្សធម៌ និងគោលការណ៍គ្រឹះរបស់ចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម រួមទាំងជំនាញ និងបំណិនផ្សេងៗ ដែលជាតម្រូវការចាំបាច់ក្នុងការងារស្ម័គ្រចិត្ត ផ្តល់សេវាកម្មមនុស្សធម៌។

៤.២. លើកទឹកចិត្តយុវជនកាកបាទក្រហមកម្ពុជា ឱ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត នៅក្នុងការបំពេញតួនាទីដ៏មានសារៈសំខាន់ និងមានគុណតម្លៃរបស់គេ នៅក្នុងការដឹកនាំគ្រប់គ្រង ការកសាងផែនការ ការអភិវឌ្ឍគោលនយោបាយ គម្រោង/កម្មវិធីនានា រួមទាំងការចូលរួមក្នុងជីវភាពអន្តរជាតិ។

៤.៣. លើកកម្ពស់ស្មារតីនៃវប្បធម៌ចែករំលែក មិត្តអប់រំមិត្ត មិត្តជួយមិត្ត ធ្វើជាគំរូនៅក្នុងចំណោមយុវជន ទាក់ទាញក្នុងនាមជាភ្នាក់ងារនៃការផ្លាស់ប្តូរឱ្យយុវជនកាន់តែច្រើនឡើងៗ កៀរគរប្រមូលផ្តុំគ្នាទៅជាកម្លាំងចលករ កសាងភាពធន់មាំរបស់សហគមន៍ ជាកម្លាំងចូលរួមដោះស្រាយបញ្ហាប្រឈមនានា ដើម្បីប្រជាពលរដ្ឋងាយរងគ្រោះ និងបន្តអភិវឌ្ឍសមាគមជាតិប្រកបដោយចេរភាព។

៤.៤. ពង្រឹង និងពង្រីក ចំណងមិត្តភាពសហប្រតិបត្តិការជាតិ-អន្តរជាតិ រវាងបណ្តាញយុវជនកាកបាទក្រហមកម្ពុជា ជាមួយអង្គការយុវជន អង្គការជាដៃគូ អង្គការអភិវឌ្ឍនានាទាំងក្នុងថ្នាក់ជាតិ តំបន់ និងលើសកលលោក។

## ៥. យុទ្ធសាស្ត្រ

៥.១. លើកទឹកចិត្តយុវជនកាកបាទក្រហមកម្ពុជា ដោយផ្តល់ឱកាសឱ្យពួកគេបានចូលរួមអនុវត្តនូវសកម្មភាព រួមទាំងផ្តល់នូវសិទ្ធិសម្រេចក្នុងដំណើរការអភិវឌ្ឍ របស់សមាគមជាតិ ដើម្បីបង្ហាញភាពជាគំរូដល់សមាជិកដទៃទៀត និងជាការទាក់ទាញយុវជនឯទៀត ឱ្យមានចំណាប់អារម្មណ៍ចូលរួមក្នុងសកម្មភាពនានារបស់កាកបាទក្រហមកម្ពុជា។

៥.២. ពង្រឹង និងពង្រីកសមត្ថភាពយុវជនកាកបាទក្រហមកម្ពុជា ក្នុងការធ្វើឱ្យប្រសើរឡើងដល់ការផ្តល់នូវសេវាកម្មមនុស្សធម៌ នៅក្នុងមូលដ្ឋានរបស់ខ្លួន ស្របតាមវិស័យស្នូលទាំង ៤ នៃយុទ្ធសាស្ត្រ ២០១១-២០២០ របស់កាកបាទក្រហមកម្ពុជា ដើម្បីធានាបាននូវនិរន្តរភាព និងការអភិវឌ្ឍនៅក្នុងកម្រិតសហគមន៍ ភូមិភាគ តំបន់ និងសកលលោក។

៥.៣. បង្កើននូវវប្បធម៌ចែករំលែក និងបណ្តុះនូវមនសិការមនុស្សធម៌ នៅក្នុងចំណោមយុវវ័យ តាមរយៈសកម្មភាព មិត្តអប់រំមិត្ត មិត្តជួយមិត្ត លើកកម្ពស់កិច្ចពិភាក្សាសហគមន៍ និងបណ្តាញព័ត៌មានទំនាក់ទំនងសង្គម ដើម្បីជានាបាននូវចេរភាព នៃកំលាំងមនុស្សធម៌នៅក្នុងសហគមន៍។

៥.៤. ពង្រឹង និងពង្រីកការផ្សារភ្ជាប់ទំនាក់ទំនងជាមួយអង្គការយុវជននានា និងអង្គការដែលជា ដៃគូអភិវឌ្ឍ ដើម្បីជានាបាននូវសុខដុមរមនីយកម្មក្នុងចំណោមយុវជន និងជួយផ្តល់ការគាំទ្រគ្នាទៅវិញទៅមក ដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះ និងជនងាយរងគ្រោះនៅក្នុងសហគមន៍។

៥.៥. កសាងផែនការសកម្មភាព ពិនិត្យតាមដាន និងវាយតម្លៃនៃកម្មវិធីអភិវឌ្ឍយុវជនកាកបាទក្រហមកម្ពុជា ទូទាំងសាខា ២៥ រាជធានី-ខេត្ត ដើម្បីជាត្រីវិស័យក្នុងការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

## ៦. ផែនការសកម្មភាព

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់លើសកម្មភាពមួយចំនួនដូចខាងក្រោម៖

### ៦.១. លើកកម្ពស់ការអនុវត្តគោលនយោបាយ

- រៀបចំឱ្យមានសេចក្តីណែនាំអភិវឌ្ឍយុវជនកាកបាទក្រហមកម្ពុជា ប្រកបដោយការពិគ្រោះយោបល់ និងមតិចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។
- ជំរុញសាខា អនុសាខា បង្កើតឱ្យមានក្រុមការងារទ្រទ្រង់សកម្មភាពយុវជនកាកបាទក្រហមកម្ពុជា និងចាត់តាំង

ឱ្យមានជនបង្គោលទទួលការងារអភិវឌ្ឍយុវជនកាកបាទក្រហមកម្ពុជា ដោយមានការជួយបច្ចេកទេស ការតម្រង់ទិស ពីក្រុមការងារទ្រទ្រង់សកម្មភាពយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា នៅថ្នាក់កណ្តាល។

- ពង្រឹងអភិបាលកិច្ចល្អ ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដល់ក្រុមការងារនៅតាមសាខា អនុសាខា ក្លឹបយុវជនកាកបាទក្រហមកម្ពុជា នៅតាមគ្រឹះស្ថានសិក្សាក្នុងទូទាំងប្រទេស។
- យុវជនកាកបាទក្រហមកម្ពុជា ត្រូវទទួលការបណ្តុះបណ្តាលជាមូលដ្ឋាន អំពីចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម គោលការណ៍គ្រឹះ វិជ្ជាសង្គ្រោះបឋម និងច្បាប់មនុស្សធម៌អន្តរជាតិ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលយុវជនកាកបាទក្រហមកម្ពុជា នឹងទទួលបានលិខិតបញ្ជាក់។

## ៦.២. ការបង្កើតយន្តការ

ផ្អែកតាមទិសវិមជ្ឈការ និងវិសហមជ្ឈការ របស់កាកបាទក្រហមកម្ពុជា សកម្មភាពយុវជនកាកបាទក្រហមតាមសាខា រាជធានី-ខេត្ត និងគ្រឹះស្ថានសិក្សា គឺគ្រប់គ្រងដោយទីស្នាក់ការកណ្តាល នឹងសាខានីមួយៗ និងទទួលបានការគាំទ្រផ្នែកបច្ចេកទេសពីទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា រួមមាន៖

- បន្តនិរន្តរភាពក្រុមការងារទ្រទ្រង់សកម្មភាពយុវជនកាកបាទក្រហមកម្ពុជា នៅថ្នាក់កណ្តាល សាខា អនុសាខា ក្រុមកាកបាទក្រហម និងនៅតាមសហគមន៍។

- ពង្រឹងនាយកដ្ឋានធនធានមនុស្ស ដើរតួនាទីជាសេនាធិការជូនក្រុមការងារទ្រទ្រង់សកម្មភាពយុវជន និងអ្នកស្ម័គ្រចិត្ត គាំទ្រផ្នែកបច្ចេកទេស និងជាមជ្ឈមណ្ឌលកណ្តាល គ្រប់គ្រងរបាយការណ៍សកម្មភាព ទិន្នន័យ និងផ្តល់ប័ណ្ណសំគាល់ខ្លួនដល់យុវជនកាកបាទក្រហមកម្ពុជា។
- យុវជនកាកបាទក្រហមកម្ពុជា ត្រូវបានផ្តល់ឱកាសក្នុងការបន្តជីវភាពជាយុវជនកាកបាទក្រហម តាមរយៈការផ្តល់លិខិតបញ្ជាក់ និងលិខិតជូនដំណឹងទៅសាខារាជធានី-ខេត្ត និងគ្រឹះស្ថានសិក្សាដែលយុវជនកាកបាទក្រហមកម្ពុជា ត្រូវបានបន្តការសិក្សា ឬផ្លាស់ប្តូរគ្រឹះស្ថានសិក្សា។
- សាខានីមួយៗ ត្រូវបានលើកទឹកចិត្តឱ្យបង្កើតយន្តការសមស្របតាមរដ្ឋបាលដែនដីនៃខេត្តរបស់ខ្លួន ដើម្បីគ្រប់គ្រងសកម្មភាពយុវជន ស្របតាមគោលនយោបាយនេះ និងគោលការណ៍គ្រឹះរបស់ចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម។

## ៦.៣. ការគាំទ្រហិរញ្ញវត្ថុ

ក្រុមការងារទ្រទ្រង់សកម្មភាពយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ប្រើប្រាស់ខ្ទង់ថវិកាអភិវឌ្ឍស្ថាប័ន/អភិវឌ្ឍសាខាដែលជាផ្នែកមួយនៃផែនការអភិវឌ្ឍរបស់កាកបាទក្រហមកម្ពុជា និងថវិកាដទៃទៀតដែលបានមកពីប្រភពផ្សេងៗដូចជា៖ សមាគមជាតិជាដៃគូ និងដៃគូអភិវឌ្ឍនានា សម្រាប់ដំណើការ ការងាររបស់ខ្លួន។

## ៧. ពិនិត្យតាមដាន និងវាយតម្លៃ

ដើម្បីឱ្យគោលនយោបាយនេះ មានវិសាលភាព និងអនុវត្តស្រប តាមបរិបទកម្ពុជា តាមទិសវិមជ្ឈការនិងសហវិមជ្ឈការរបស់កាកបាទក្រហមកម្ពុជា ចាំបាច់ត្រូវមានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ និងសំណើកែលម្អឡើងវិញអនុវត្តដោយផ្តោតទៅលើ ៖

- គោលនយោបាយនេះ ត្រូវពិនិត្យវាយតម្លៃនៅឆ្នាំ២០១៧។
- ប្រជុំបូកសរុបការងារយុវជនកាកបាទក្រហមកម្ពុជា ប្រចាំឆ្នាំ គឺជាផ្នែកមួយនៃការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីលើកទិសដៅអនុវត្តសម្រាប់ឆ្នាំបន្ទាប់។
- ប្រៀបធៀបលទ្ធផលដែលទទួលបាន ទៅនឹងចំណុចដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនៃគោលនយោបាយនេះ។

## ៨. សេចក្តីសន្និដ្ឋាន

គោលនយោបាយយុវជនកាកបាទក្រហមកម្ពុជា មានគោលបំណងទទួលស្គាល់ពីបំណងប្រាថ្នា តម្រូវការ និងលក្ខខណ្ឌរបស់យុវជនកាកបាទក្រហមកម្ពុជា ដោយបានបញ្ជាក់ច្បាស់ពី ចក្ខុវិស័យ គោលបំណង ទិសដៅ និងយុទ្ធសាស្ត្រមួយចំនួន ដើម្បីប្រមូលកម្លាំងយុវជនពីគ្រប់មជ្ឈដ្ឋាន និងកៀរគរធនធាន សំដៅអភិវឌ្ឍយុវជនឱ្យក្លាយទៅជាអ្នកស្ម័គ្រចិត្តវ័យក្មេង មានទាំងកាយសម្បទា មានទឹកចិត្តមនុស្សធម៌ មានចំណេះដឹង ចំណេះធ្វើ មានសាមគ្គីភាពទូលំទូលាយ មានគំនិតផ្តួចផ្តើម និងការច្នៃប្រឌិតក្នុងការរៀបចំផែនការសកម្មភាព សំដៅលើកស្ទួយប្រសិទ្ធភាព ក្នុងការផ្តល់សេវាកម្មមនុស្សធម៌ ឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ និងងាយរងគ្រោះ ដើម្បីរួមចំណែកក្នុងការពន្លឿនការកាត់បន្ថយភាពក្រីក្រ ការពារនិងលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ធ្វើឱ្យកិត្យានុភាពរបស់កាកបាទក្រហមកម្ពុជា ត្រូវបានលើកកម្ពស់ទាំងក្នុងថ្នាក់ជាតិ និងអន្តរជាតិ។